# رسالة موجزة إلى ملحد

# សារសង្ខេបជូនចំពោះអ្នកដែលបដិសេធវត្តមានរបស់អល់ឡោះព្រះជាម្ចាស់

## សារសង្ខេបជូនចំពោះអ្នកដែលបដិសេធវត្តមានរបស់អល់ឡោះព្រះជាម្ចាស់

គណៈកម្មការវិទ្យាសាស្ត្រនៃសមាគមបម្រើមាតិកាអ៊ីស្លាមពហុភាសា

## សារសង្ខេបជូនចំពោះអ្នកដែលបដិសេធវត្តមានរបស់អល់ឡោះព្រះជាម្ចាស់

គណៈកម្មការវិទ្យាសាស្ត្រនៃសមាគមបម្រើមាតិកាអ៊ីស្លាមពហុភាសា

យើងរស់នៅក្នុងសកលលោកដ៏អស្ចារ្យមួយ ដែលត្រូវបានគ្រប់គ្រងដោយប្រព័ន្ធច្បាប់ដ៏ជាក់លាក់ ដែលបង្ហាញពីភាពស៊ីសង្វាក់ និងសណ្តាប់ធ្នាប់ដ៏ល្អឥតខ្ចោះដែលពិតជាធ្វើឱ្យមនុស្សយើងមានការភ្ញាក់ផ្អើល។

នៅពេលដែលមនុស្សយើងកាន់តែសិក្សាស៊ីជម្រៅអំពីច្បាប់នៃសកលលោក

នោះនឹងមានសំណួរមួយលេចឡើងដែលវិទ្យាសាស្ត្រមិនអាចផ្តល់ចម្លើយបានឡើយនោះគឺៈ តើច្បាប់ទាំងនេះមកពីណា? ហើយហេតុអ្វីបានជាវាមានឡើងតាំងពីដំបូង?

ខ្ញុំមកនេះមិនមែនផ្តល់ចម្លើយតែម្តងនោះទេ ក៏ប៉ុន្តែខ្ញុំសូមលើកយកសំណួរដែលសមទំនងដើម្បីធ្វើការគិតពិចារណាទាំងអស់គ្នា ដោយមិនគិតពីការយល់ឃើញនៃសាសនា ឬទស្សនៈណាមួយឡើយ។

តើសមទំណងទេចំពោះការលើកឡើងថា ច្បាប់ទាំងនេះកើតចេញពីភាពទទេ? តើច្បាប់ត្រូវបានបង្កើតមកដោយគ្មានគោលបំណង? តើការយល់ដឹងអាចកើតចេញពីធាតុដែលគ្មានបញ្ញាបានដែរទេ?

ចូរយើងចាប់ផ្តើមដំបូង អំពីសំណួរដ៏ជាក់លាក់ និងស៊ីជម្រៅបំផុតនៅពេលនេះៈ

តើភាពទទេអាចបង្កើតអ្វីបានទេ?

តើសមទំណងទេចំពោះការលើកឡើងថា សកលលោកដែលមានសណ្តាប់ធ្នាប់អស្ចារ្យបែបនេះ ក៏ដូចជាភាពស៊ីសង្វាក់គ្នាដ៏ល្អឥតខ្ចោះនៃប្រព័ន្ធច្បាប់របស់វា កើតឡើងពីភាពទទេ និងដោយគ្មានមូលហេតុនោះ?

បញ្ញាត្រឹមត្រូវរបស់មនុស្សពិតជាបដិសេធទាំងស្រុងចំពោះគំនិតនេះ ព្រោះនៅក្នុងជីវិតប្រចាំថ្ងៃរបស់យើង

គឺយើងមិនឃើញអ្វីមួយដែលកើតឡើងពីភាពទទេឡើយ។
សូមពិចារណាអំពីខ្លួនឯងៈ
តើអ្នកណាដែលបង្កើតខ្ញុំពីទឹកមួយតំណក់ដ៏តូច(គ្មានតម្លៃ)
ហើយបានធ្វើឱ្យអ្នកក្លាយជាមនុស្សដែលស្តាប់ឮ និងមើលឃើញ?
តើអ្នកណាបង្កើតរូបកាយរបស់ខ្ញុំឱ្យមានភាពល្អឥតខ្ចោះបែបនេះ ផ្តល់ឱ្យខ្ញុំនូវភ្នែកសម្រាប់មើល ត្រចៀកសម្រាប់ស្តាប់ និងបញ្ញាសម្រាប់វិភាគ និងគិតពិចារណា??
តើអ្នកណាផ្គត់ផ្គង់ខ្ញុំ
កាលខ្ញុំនៅក្នុងផ្ទៃម្តាយរបស់ខ្ញុំ
ខណៈដែលខ្ញុំមិនអាចធ្វើអ្វី
ឬគ្មានសមត្ថភាពអ្វីឡើយ។
តើអ្នកណាផ្តល់អាហារដល់ខ្ញុំតាមរយៈឈាមរបស់ម្តាយខ្ញុំ
និងរៀបចំអ្វីគ្រប់យ៉ាងសម្រាប់ការលូតលាស់របស់ខ្ញុំ និងការចេញមកក្នុងជីវិតនេះ?
តើអ្នកបានធ្វើវាដោយខ្លួនឯង?
ឬធម្មជាតិដែលគ្មានបញ្ញាបានធ្វើវា?
ធម្មជាតិ គឺគ្មានបញ្ញា គ្មានចេតនា និងគ្មានឆន្ទៈឡើយ។
តើវាអាចបង្កើតឱ្យមានសណ្តាប់ធ្នាប់ចំពោះរឿងដ៏សែនស្មុគស្មាញជាងកុំព្យូទ័របានយ៉ាងដូចម្តេច?

តើវាអាចបង្កើតប្រាជ្ញាស្មារតី ការយល់ដឹង និងអារម្មណ៍បានយ៉ាងដូចម្តេច?

តើធម្មជាតិអាចដាក់នូវសេចក្តីស្រឡាញ់នៅក្នុងបេះដូងរបស់ម្តាយចំពោះកូនរបស់នាងបានយ៉ាងដូចម្តេច? ឬធ្វើឱ្យបេះដូងរបស់អ្នកតក់ស្លុតឬឈឺចាប់នៅពេលឃើញភាពអយុត្តិធម៌ និងរីករាយនិងបានស្ងើយនៅពេលឃើញភាពយុត្តិធម៌បានយ៉ាងដូចម្តេច?

តើអ្នកណាជាអ្នកដែលដាំនូវគុណតម្លៃដ៏ខ្ពង់ខ្ពស់ទាំងនេះនៅក្នុងខ្លួនរបស់យើង?
តើគុណតម្លៃទាំងនេះមកពីណា?
តើមនសិការមកពីណា?

អ្វីគ្រប់យ៉ាងនៅជុំវិញយើងបានស្រែកប្រាប់ថាពិតជាមានអ្នកដែលបង្កើត។

សូមក្រឡេកមើលទៅកាន់មេឃ៖
តើអ្នកណាបានលើកវាឡើងដោយគ្មានសសរទ្រ?

សូមក្រឡេកមើលទៅកាន់ព្រះអាទិត្យ៖
តើអ្នកណាបានកំណត់គន្លងរបស់វាឱ្យមានភាពជាក់លាក់ និងគ្មានការផ្លាស់ប្តូរបែបនេះ?

សូមក្រឡេកមើលទៅបេះដូងរបស់អ្នក៖
តើអ្នកណាធ្វើឱ្យវាលោតឥតឈប់ពេញមួយជីវិតដោយមិនចាំបាច់មានការបញ្ជាពីអ្នកនោះ?

តើអ្វីទាំងអស់នេះកើតឡើងដោយចៃដន្យឬ? ហើយតើការចៃដន្យអាចកើតឡើងម្តងហើយម្តងទៀត

គរាប់ពាន់លានដងជាមួយនឹងសណ្តាប់ធ្នាប់បែបនេះបានទេ?

តើអ្នកជឿទេថា សៀវភៅដ៏ជាក់លាក់មួយដូចជាវចនានុក្រម ឬសព្ទវចនាធិប្បាយបានលេចចេញមកដោយចៃដន្យពីការផ្ទុះនៃម៉ាស៊ីនបោះពុម្ពដែរឬទេ?

បើដូច្នេះ តើអ្នកជឿយ៉ាងដូចម្តេចថា សកលលោកដ៏សែនអស្ចារ្យជាងសៀវភៅទាំងអស់នោះបានលេចចេញមកពីការផ្ទុះឡើងដោយងងឹតងងល់មែនទេ?

សាសនាអ៊ីស្លាមមិនអំពាវនាវឱ្យអ្នកបញ្ឈប់ការប្រើប្រាស់បញ្ញារបស់អ្នកទេ ប៉ុន្តែជំរុញឱ្យអ្នកប្រើប្រាស់វាទៅវិញទេ។ អល់ឡោះជាម្ចាស់បានមានបន្ទូលនៅក្នុងព្រះគម្ពីរគួរអាន៖

﴿...أَفِي ٱللَّهِ شَكٌّ فَاطِرِ ٱلسَّمَٰوَٰتِ وَٱلۡأَرۡضِۖ...﴾

﴿...តើពួកអ្នកមានការសង្ស័យចំពោះអល់ឡោះដែលជាអ្នកបង្កើតមេឃជាច្រើនជាន់ និងផែនដីឬ? ﴾ ជំពូក ១៤ : ១០

តើអ្នកមានការសង្ស័យចំពោះវត្តមាននៃអ្នកបង្កើតមេឃជាច្រើនជាន់ និងផែនដីឬ?

ទ្រង់បានមានបន្ទូលថា៖

﴿وَفِيٓ أَنفُسِكُمۡۚ أَفَلَا تُبۡصِرُونَ 21﴾

ហើយចំពោះខ្លួនពួកអ្នកផ្ទាល់ក៏ដូច្នោះដែរ តើពួកអ្នកមិនឃើញទេឬ? ជំពូក ៥១ : ២១

នេះគឺជាការអំពាវនាវមួយ ដើម្បីឱ្យអ្នកសញ្ជឹងគិតអំពីរាងកាយ និងព្រលឹងរបស់អ្នក ដើម្បីឱ្យអ្នកបានមើលឃើញអំពីភស្តុតាងដែលនៅចំពោះមុខអ្នក។

បន្ទាប់មក សូមសញ្ជឹងគិតអំពីព្រះគម្ពីរគួរអាន ដែលជាគម្ពីរចុងក្រោយបង្អស់របស់ព្រះជាម្ចាស់។

ព្រះគម្ពីរនេះបានបញ្ចុះមកជាង ១៤០០ ឆ្នាំមុនមកម្លេះ ដោយទ្រង់បានប្រកួតប្រជែងមនុស្សជាតិឱ្យនាំមកនូវអ្វីដែលស្រដៀងនឹងព្រះគម្ពីរនេះ ប៉ុន្តែពួកគេមិនអាចធ្វើបានឡើយ។

ព្រះគម្ពីរនេះបានបញ្ចូលគ្នានូវគោលជំនឿ បញ្ញត្តិច្បាប់ ប្រវត្តិសាស្ត្រ វិទ្យាសាស្ត្រ និងរចនាបថនៃភាសាដែលគ្មានអ្វីប្រៀបផ្ទឹមបានឡើយ។

ព្រះគម្ពីរក៏បានប្រាប់អំពីជនជាតិដែលបានវិនាស អំពីព្រឹត្តិការណ៍ដែលបានកន្លងហួស និងរបកគំហើញដែលមិនត្រូវបានគេដឹងរហូតដល់សតវត្សរ៍ចុងក្រោយនេះ ដូចជា៖ ការលូតលាស់នៃទារកក្នុងផ្ទៃ បណ្តុំនៃពពកស្រទាប់ផែនដី និងភាពជាក់លាក់នៃចលនារបស់ភព។

បន្ទាប់មក សូមសញ្ជឹងគិតអំពីជីវប្រវត្តិរបស់ព្យាការីមូហាំម៉ាត់

(សូនសុខសន្តិភាពកើតមានដល់លោក)។ លោកជាបុរសម្នាក់ដែលធំធាត់នៅទីវាលខ្សាច់ឆ្ងាយពីមជ្ឈមណ្ឌលនៃអរិយធម៌ មិនចេះអាន មិនចេះសរសេរ និងមិនបានទទួលការអប់រំពីមនុស្សណាម្នាក់ ប៉ុន្តែលោកបានបង្ហាញនូវសារដ៏អស់កល្បជានិច្ចដល់មនុស្សជាតិ ដែលបំភ្លឺចិត្ត បន្សុទ្ធព្រលឹង និងនាំមកនូវការផ្លាស់ប្តូរដ៏ធំធេងនៅក្នុងដំណើរប្រវត្តិសាស្ត្រ។

ជាមួយនឹងព្រះបន្ទូលដែលបានចុះមកកាន់លោកនៅក្នុងរូងភ្នំមួយ លោកបានផ្លាស់ប្តូរមនុស្សជាតិពីការគោរពបូជាមនុស្ស និងថ្មទៅជាការគោរពសក្ការៈព្រះជាម្ចាស់តែមួយគត់ ដែលជាអ្នកបង្កើតសកលលោក និងបានបង្កើតគុណតម្លៃនៃយុត្តិធម៌ សេចក្តីមេត្តាករុណា និងសេចក្តីថ្លៃថ្នូរ។

តើអ្វីទៅជាថាមពលដ៏អស្ចារ្យនេះ ដែលបានផ្លាស់ប្តូរពិភពលោក ពាល់ដល់បេះដូង និងនៅតែបន្លឺសូរស័ព្ទ ទោះបីជាបានកន្លងផុតទៅរាប់សតវត្សរ៍ហើយនោះ?

ឱ អ្នករាល់គ្នាដែលកំពុងតែអាននូវពាក្យពេចន៍ទាំងនេះ៖ ពិតប្រាកដណាស់

ព្រះជាម្ចាស់របស់យើងមិនត្រូវការអ្វីពីយើងទេ ប៉ុន្តែយើងទេជាអ្នកដែលត្រូវការទ្រង់។

ទ្រង់ជាអ្នកបង្កើតយើង ផ្តល់លាភសក្ការៈដល់យើង ការពារយើង និងផ្តល់ឱកាសឱ្យយើងដើម្បីបានសញ្ជឹងគិត និងវិលត្រឡប់មករកទ្រង់វិញ។

ទ្រង់មិនប្រព្រឹត្តិអយុត្តិធម៌ចំពោះនរណាម្នាក់ឡើយ ហើយអ្នកណាដែលត្រឡប់ទៅរកទ្រង់ដោយស្មោះនោះ ទ្រង់ប្រកដជានឹងទទួលយកការសុំអភ័យទោស និងប្រែក្លាយអំពើអាក្រក់របស់គេទៅជាអំពើល្អវិញជាមិនខាន។

ខ្ញុំមិនបង្ខំអ្វីអ្នកទេ ប៉ុន្តែខ្ញុំគ្រាន់តែចង់ឱ្យអ្នកបានផ្តល់ឱកាសដល់បេះដូងរបស់អ្នកមានភាពស្មោះត្រង់ចំពោះការពិតប៉ុណ្ណោះ។

ដើម្បីអ្នកបានដកនូវកំហឹង និងភាពចលាចលក្នុងចិត្ត ហើយសញ្ជឹងគិតមួយភ្លែតថា៖

ចុះបើខ្ញុំខុស?

ចុះបើមានព្រះជាម្ចាស់មានពិត មានជីវិតក្រោយស្លាប់ មានឋានសួគ៌ និងឋាននរកនោះ?

តើខ្ញុំនឹងស្តាយក្រោយនៅពេលនោះទេ នៅពេលដែលការស្តាយក្រោយមិនបានផ្តល់ប្រយោជន៍ និងមិនអាចជួយអ្វីបាននោះ?

សូមបោះជំហានដ៏ស្មោះត្រង់ឆ្ពោះទៅរកការពិត ហើយចាប់ផ្តើមដំណើររបស់អ្នកជាមួយនឹងការណែនាំនៃព្រះគម្ពីរគួរអាន...
នោះអ្នកនឹងរកឃើញចម្លើយចំពោះសំណួរដែលអ្នកបានតាមរកមកជាយូរ
និងទទួលបាននូវពន្លឺនៃការចង្អុលបង្ហាញដែលអ្នកធ្លាប់បាត់បង់កន្លងមក។

ការបកប្រែអត្ថន័យនៃព្រះគម្ពីរគួរអាន។

# Index

សារសង្ខេបជូនចំពោះអ្នកដែលបដិសេធវត្តមានរបស់អល់ឡោះព្រះជាម្ចាស់ ........ 2
សារសង្ខេបជូនចំពោះអ្នកដែលបដិសេធវត្តមានរបស់អល់ឡោះព្រះជាម្ចាស់ ........ 2

km438v2.0 - 06/09/2026